**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាជរដ្ឋសភា និងព្រឹទ្ធសភា**
លេខ៖ ០៤ ញ/០៦ ២៥/សភ.ម

# សេចក្ដីសម្រេច
# ស្ដីពី
# ប្រព័ន្ធគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី៥
- យោងលទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ស្ដីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា នីតិកាលទី៥
- យោងលទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការនានានៃរដ្ឋសភា នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣
- យោងលិខិតលេខ ២៣៧ លស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ របស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីសេចក្ដីស្នើសុំកោះប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីពិភាក្សាលើប្រធានបទសំខាន់ចំនួន៣ របស់ប្រទេសជាតិ
- យោងលទ្ធផលនៃអង្គប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥

## សម្រេច

**មាត្រា១.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា គាំទ្រទាំងស្រុងនូវទិសដៅយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលស្របនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជា ទាំងបច្ចុប្បន្ន និងទៅអនាគត ក្នុងរយៈពេលនៃអាណត្តិទី៧។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២១១ ៤៤១, ២១១ ៤៤២, ២១១ ៤៤៣ ទូរសារ: (៨៥៥-២៣) ២២១ ៤៤៦, E-mail: secretariat@senate.gov.kh

**មាត្រា២.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា គាំទ្រទាំងស្រុងនូវការអនុវត្ត យុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងឡាយរបស់រាជរដ្ឋាភិបាលដែលផ្តល់នូវសមិទ្ធផលនៃប្រព័ន្ធ គាំពារសង្គម ដែលបានលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព និងគុណភាពជីវិតរបស់ពលរដ្ឋ រួមទាំងបានជួយរក្សាលំនឹងជីវភាពក្នុងអំឡុងជួបគ្រោះអាសន្ន។

**មាត្រា៣.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា លើកទឹកចិត្តរាជរដ្ឋាភិបាលឱ្យបន្ត អភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដោយពង្រឹងអភិបាលកិច្ច ប្រកាន់ខ្ជាប់នូវអភិក្រម «ជវភាពនៃប្រព័ន្ធ តួអង្គតែមួយ» និងបន្តអនុវត្តគោលនយោបាយគាំពារសង្គម ក្នុងកម្មវិធីគោលនយោបាយអាទិភាព និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ដែលបន្តផ្តល់ការទ្រទ្រង់ ជីវភាពដល់ពលរដ្ឋគ្រប់រូប ជាពិសេសពលរដ្ឋក្រីក្រ និងងាយរងហានិភ័យ តាមរយៈការពង្រឹងយន្ត ការអនុវត្ត ការពង្រីកវិសាលភាពនៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ជាជំហានៗ ប្រកបដោយប្រសិទ្ធភាព តម្លាភាព បរិយាបន្ន និងកាន់តែមានភាពងាយស្រួលក្នុងការទទួលបាន រួមទាំងបន្តពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល និងជំរុញការកែ ទម្រង់របបសោធននានា ដោយបង្កើតនូវប្រព័ន្ធសោធនជាតិរួម ដែលមាននិរន្តរភាព។

**មាត្រា៤.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា លើកទឹកចិត្តឱ្យព្រឹទ្ធសភា និង រដ្ឋសភា បន្តគាំទ្ររាជរដ្ឋាភិបាលក្នុងការអនុម័តច្បាប់ទាំងឡាយ ដែលជួយដោះស្រាយនូវបញ្ហា ប្រឈម និងតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

**មាត្រា៥.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋគ្រប់ ស្រទាប់វណ្ណៈ ដែលបានគាំទ្រចំពោះកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងសូមអំពាវនាវបន្ត ចូលរួមថែរក្សាសន្តិភាពនិងការអភិវឌ្ឍឱ្យបានគង់វង្សនិងមានចីរភាពជានិរន្តន៍។

**មាត្រា៦.-**

ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និង ស្ថាប័នមានសមត្ថកិច្ច ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសេចក្តីសម្រេចនេះ។

**មាត្រា៧.-**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៨ កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៥ នស.រល

**ប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**
-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-ស្ថាប័នមានសមត្ថកិច្ច
"ដើម្បីជូនជ្រាប និងអនុវត្ត "
-ឯកសារ កាលប្បវត្តិ